ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ៤៣៥-សណ.១៧ អអក

ភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ សហគ្រាស ថ្នល់បែក ចំការលើ អេឡិកទ្រីស៊ីធី សម្រាប់ធ្វើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃស្រុកចំការលើ ខេត្តកំពង់ចាម

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់ សហគ្រាស ថ្នល់បែក ចំការលើ អេឡិកទ្រីស៊ីធី ដើម្បីអនុញ្ញាតឲ្យពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយដែលមានស្រាប់ និងដកតំបន់ចែកចាយអគ្គិសនីមួយផ្នែកនៃភូមិវាលវីលិច ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម តាមខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងផ្តល់ជូនសហគ្រាស ថ្នល់បែក ចំការលើ អេឡិកទ្រីស៊ីធី ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ................................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យសហគ្រាស ថ្នល់បែក ចំការលើ អេឡិកទ្រីស៊ីធី អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **“អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណាដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ”** ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

**សេចក្តីព្រាង**

# អាជ្ញាធរអគ្គិសនីកម្ពុជា

**ELECTRICITY AUTHORITY OF CAMBODIA**

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

## សេចក្តីសម្រេចកែសម្រួលលើកទី១១
## លើឯកសារអាជ្ញាបណ្ណលេខ ០៣៨ ឯអ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៣ សម្រាប់សហគ្រាស ថ្នល់បែក ចំការលើ អេឡិកទ្រីស៊ីធី ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកចំការលើ ខេត្តកំពង់ចាម

## សម្រាប់ការដកតំបន់ចែកចាយ និងការពង្រីកតំបន់ចែកចាយ

**DECISION ON THE ELEVENTH REVISION**

TO THE LICENSE DOCUMENT No. 038 LD DATED MAY 20, 2003 FOR TNAL BEK CHAMCAR LEU ELECTRICITY ENTERPRISE FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF CHAMKAR LEU DISTRICT, KAMPONG CHAM PROVINCE

**FOR WITHDRAWING DISTRIBUTION AREA AND EXTENDING DISTRIBUTION AREA**

ថ្ងៃទី ខែ ឆ្នាំ២០១៧

… … …, 2017